អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ទស្សនៈរបស់លោករូសូ  សង្គមវិទូបស្ចឹមប្រទេស
## ប្រៀបមកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ (តពីលេខមុន)

www.hoksavann.org

ថ្ងៃទី១ សីហា ២០១២



ដូចបានពោលពីអត្ថបទមុន លោកហ្សង់ហ្សាក់-រូសូ ជាសង្គមវិទូម្នាក់នៅបស្ចឹមប្រទេសសតវត្សរ៍ទី១៨បាននិយាយថា តាមធម្មជាតិ មនុស្សកើតមកល្អទេ តែដែលឲ្យមនុស្សទៅជាអាក្រក់ ដោយសារសង្គម ។ តទៅនេះ យើងសូមវិភាគតទៅទៀត ដោយប្រៀបមកព្រះពុទ្ធសាសនា ។

លោករូសូនិងពួកចិត្តវិទូខ្លះនិយាយថា កុមារវ័យក្មេងនៅពេលដែលមិនទាន់ទទួលអារម្មណ៍ពីខាងក្រៅ មានខួរក្បាលល្អណាស់ ប្រៀបដូចសំពត់ស ដែលមិនទាន់ប៉ះទឹកជ្រលក់ណាមួយ ។ លុះប៉ះទឹកជ្រលក់ ក៏វាប្រែពណ៌ទៅតាមពណ៌ទឹកជ្រលក់ ។ លោករូសូមានទុទិដ្ឋិនិយមទៅលើសង្គម ថាមនុស្សអាក្រក់ដោយសារសង្គម ។ តាមពិតសង្គមមនុស្សពុំមែនអាក្រក់ទេ ជាសង្គមប្រសើរជាងសង្គមសត្វតិរច្ឆាន ព្រោះមនុស្សជាសត្វមានបញ្ញា ចេះរៀបចំសង្គមខ្លួនឲ្យបានចំរើនលូតលាស់ស្មើរគ្រប់វិស័យ ខាងវត្ថុសម្ភារៈនិងខាងសីលធម៌ មានអារ្យធម៌កាន់តែខ្ពស់ឡើង ។ តាមសេចក្តីពិត ទស្សនៈរបស់លោករូសូនិងពួកចិត្តវិទូ ពុំត្រឹមត្រូវទាំងអស់ឡើយ ព្រោះដោយសារសង្គមមានបញ្ញាបង្កើតបាននូវតិចនិកនិងបច្ចេកទេសយ៉ាងខ្ពស់ ដើម្បីបំរើមនុស្សលោក ដូចជាប្រដាប់ប្រដាប្រើប្រាស់ គមនាគមន៍ ចំណីអាហារបរិភោគ ថ្នាំសំរាប់កែរោគជាដើម រហូតបង្កើតលទ្ធិប្រជាធិបតេយ្យសំរាប់ដឹកនាំស្រុកទេសផង ។ បើគ្មានសង្គមមនុស្សទេ មនុស្សលោកនឹងក្លាយជាសង្គមសត្វ គ្មានចំរើនលូតលាស់អ្វីឡើយ ។

តាមព្រះពុទ្ធសាសនាវិញ មនុស្សគ្រប់រូបដែលទៅជាល្អអាក្រក់បែបណានោះ ពុំមែននៅតែលើសង្គមប៉ុណ្ណោះទេ គឺនៅលើនិស្ស័យវាសនារបស់ខ្លួនពីអតីតជាតិផង ។ ប្រៀបដូចគ្រាប់ពូជ បើគ្រាប់ពូជល្អ យកទៅដាំក្នុងដីមានជីជាតិល្អ គ្រាប់ពូជនោះអាចដុះលូតលាស់ល្អ ។ យ៉ាងណាមិញ ចិត្តមនុស្សកើតមកពុំមែនល្អទាំងអស់ដូចជាសំពត់សនោះទេ ដោយភាពនិស្ស័យខុសគ្នានេះហើយ បានជាគេអប់រំចិត្តក្នុងពេលជាមួយគ្នា មនុស្សនៅតែមានចរិតលក្ខណៈខុសគ្នា ដោយសារនិស្ស័យវាសនាជាគ្រាប់ពូជខុសគ្នា ។ តាមបរមត្ថអភិធម្ម ល្អអាក្រក់ស្ថិតនៅលើចលនារបស់ចិត្តដែលប្រព្រឹត្តនៅក្នុងអារម្មណ៍ស្រឡាញ់ឬស្អប់ឬជាឧបេក្ខា ពុំមែនពីសង្គមឡើយ ។ គម្ពីរធម្មបទនិយាយថា ភវង្គចិត្តជាចិត្តមានពន្លឺរស្មីស្អាតល្អណាស់ តែអាគន្តុកចិត្តចូលមក បានធ្វើឲ្យចិត្តទៅជាកករល្អក់ ។ ត្រង់ពាក្យនេះ ពុំមែនបានន័យថា ចិត្តបរិសុទ្ធរួចមកហើយពីកំណើតទេ បើចិត្តបរិសុទ្ធរួចហើយវិញ ព្រះពុទ្ធមិនចាំបាច់សំដែងឲ្យមនុស្សអប់រំចិត្តធ្វើអ្វីទៀតទេ ។ តាមសេចក្តីពិត ភវង្គៈនេះជាប្រដាប់សំរាប់បង្កើតចេតនា គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយនៅល្អ សំរាប់បង្កើតវិញ្ញាណ កាលណារូប សម្លេង ក្លិន រស់ និងសម្ផស្សមកប៉ះ ។ គួរហៅត្រឹមភវង្គនេះឡើងកាន់វិថីចិត្តជាច្រើនខណៈទៀត ។ ត្រង់ពាក្យថា ភវង្គចិត្តមានពន្លឺរស្មីល្អនោះ គ្រាន់តែមានន័យថា ចិត្តកាលណាអារម្មណ៍មិនទាន់មកប៉ះ មិនទាន់ប្រាកដថា ជាចិត្តប្រភេទណានៅឡើយ ហាក់ដូចជាចិត្តស្ងប់ល្អបរិសុទ្ធទុកដូចគ្រាប់រុក្ខជាតិដែលគេពុំទាន់យកទៅដាំ តាមការពិត ដើម មែក ស្លឹក ផ្លែ ផ្កា វាមាននៅក្នុងគ្រាប់ពូជនោះរួចហើយ យ៉ាងណាមិញ អវិជ្ជា តណ្ហា ឧបាទាន វាមាននៅក្នុងចិត្ត ប៉ុន្តែវាពុំទាន់ចេញសកម្មភាព ដោយពុំទាន់បានទទួលអារម្មណ៍ ។

ចំពោះជំនឿលើនិស្ស័យ វាសនា ក្នុងអតីតជាតិ មានភស្តុតាងជាច្រើនបានបញ្ជាក់ ដែលនាំឲ្យចិត្តជឿជាក់បាន ។ និស្ស័យវាសនា ឬកម្មផលពីអតីតជាតិប្រៀបជាសាមញ្ញ ដូចមនុស្សទៅផ្សារបំណាងទិញអ្វីមួយ ហើយភ្លេចនៅពេលចេញពីផ្ទះ លុះដើរមើលទំនិញក្នុងផ្សារ ស្រាប់តែឃើញវត្ថុដែលខ្លួនបំណាងទិញពីផ្ទះទៅ ទើបនឹកឃើញ ។ យ៉ាងណាមិញ និស្ស័យ វាសនា ឬកម្មផលមានចំណេះដឹងជាដើម ដែលបុគ្គលបានសិក្សាក្នុងអតីតជាតិ លុះជាតិមួយទៀត ពិតមែនតែត្រូវរលត់ ឬភ្លេចអស់តែបានជាឧបនិស្ស័យ ធ្វើឲ្យបុគ្គលនោះរៀនឆាប់ចេះឆាប់ចាំ កាលណាបានសិក្សាវិជ្ជាដូចគ្នានេះក្នុងជាតិមួយទៀត គឺនិស្ស័យពីមុនផ្សំនិងហេតុការណ៍បច្ចុប្បន្នផង ។ បើគ្មាននិស្ស័យពីមុនផ្សំផងទេ បុគ្គលនោះរៀនក្រចេះក្រចាំ បានជាគេឃើញសិស្សរៀននៅថ្នាក់ជាមួយគ្នា សិស្សខ្លះពូកែ សិស្សខ្លះខ្សោយ ដោយមានឧបនិស្ស័យផ្សេងៗគ្នា ផ្សំនឹងកត្តាផ្សេងៗទៀត ។ ក្នុងន័យនេះហើយ បានជាគេឲ្យនិស្សិតរៀនថ្នាក់ខ្ពស់ជ្រើសរើសវិជ្ជាសិក្សាតាមនិស្ស័យចូលចិត្តរបស់ខ្លួន ។ ចំណែកលោករូសូពុំនិយាយពីនិស្ស័យ វាសនា របស់មនុស្សឲ្យច្បាស់លាស់ដូចជាព្រះពុទ្ធអង្គឡើយ ។

របបកុម្មុយនិស្តផ្តាច់ការរបស់ខ្មែរក្រហម បានបង្ខំឲ្យខ្មែរមានចិត្តស្មើគ្នាតាមមតិរបស់គេ រហូតទ្រព្យសម្បត្តិឲ្យស្មើគ្នាទៀត តែពួកវាត្រូវបរាជ័យព្រោះប្រឆាំងនឹងធម្មជាតិរបស់មនុស្ស រហូតពួកវាសម្លាប់ខ្មែររាប់លាននាក់ ។ ប្រទេសជឿនលឿនដែលកាន់របបប្រជាធិបតេយ្យសេរី  គេប្រើសិទ្ធិឲ្យប្រជាពលរដ្ឋបញ្ចេញនូវបញ្ញាស្មារតីស្រាវជ្រាវនិងពិសោធន៍រកអាថ៌កំបាំងក្នុងធម្មជាតិ ដើម្បីអភិវឌ្ឍន៍សង្គម ហើយរដ្ឋជួយឧបត្ថម្ភទៀតផង គឺរដ្ឋបើកឲ្យស្មើគ្នាចំពោះមុខច្បាប់ ។៚

*   *

*